ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

សាលាឧទ្ធរណ៍

**តាងនាមប្រជារាស្ត្រខ្មែរ**

សំណុំរឿងព្រហ្មទណ្ឌ

លេខ ៧៥/២២-០១-១៣

សាលាឧទ្ធរណ៍ភ្នំពេញ

បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជម្រះក្តី ដែលប្រកាសឲ្យប្រើតាមព្រះរាជក្រមលេខ នស/រកម/០៧១៤/០១៥ ចុះថ្ងៃទី១៦ ខែកក្កដា ឆ្នាំ២០១៤ បានបើកសវនាការជាសាធារណៈនៅសាលាឧទ្ធរណ៍នាថ្ងៃទី ៣០-៩-២០១៤ ដែលមានសមាសភាពដូចតទៅ៖

**សាលដីកា**

លេខ ៥៨ ក្រ.ឧ.ឃ.ចុះ

ថ្ងៃទី ០៩-១០-២០១៤

**សមាសភាពក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ប្រធាន

លោក [redacted] ចៅក្រមប្រឹក្សា

លោក [redacted] ចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

បានបើកសវនាការជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌដែលមានលេខ ៧៥ ចុះថ្ងៃទី ២២-០១-២០១៣ រវាង ៖

-ជនជាប់ចោទឈ្មោះ:

១-[redacted] **ហុង** ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ មុខរបរ សន្តិសុខក្រុមហ៊ុនឬស្សីមហ្សេរី ទីកន្លែងកំណើត និងសព្វថ្ងៃភូមិ[redacted] ឪពុកឈ្មោះ[redacted](ស្លាប់) ម្តាយឈ្មោះ[redacted](ស្លាប់) នៅលីវ ទោសពីមុនគ្មាន (ឃុំខ្លួន)។ មានមេធាវីការពារសិទ្ធិឱ្យឈ្មោះ [redacted] **សារី**។ (ប្តឹងឧទ្ធរណ៍)

២-[redacted] **ថា** ភេទប្រុស អាយុ២១ឆ្នាំ (គេចខ្លួន)

**ត្រូវជាប់ចោទពីបទ** ៖ លួចដោយសារការប្រព្រឹត្តអំពើហិង្សា

ប្រព្រឹត្តនៅភូមិឃ្លាំងសម្បត្តិ ឃុំពត់ស ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី ១៨-៣-២០១១ តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៣-[redacted] **ទុំ** ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ (មិនប្តឹងឧទ្ធរណ៍)

៤-[redacted] វាសនា ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ (មិនប្តឹងឧទ្ធរណ៍)

៥-[redacted] បូរី ភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ (មិនប្តឹងឧទ្ធរណ៍)

**ត្រូវបានចោទពីបទ** ៖ សមគំនិតក្នុងអំពើលួចដោយសារការប្រព្រឹត្តហិង្សា

ប្រព្រឹត្តនៅភូមិឃ្លាំងសម្បត្តិ ឃុំពត់ស ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី ១៨-៣-២០១១ តាមមាត្រា ២៩,៣៥៧ នៃក្រមព្រហ្មទណ្ឌ។

-ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ភេទប្រុស អាយុ២៩ឆ្នាំ ជនជាតិចិន មុខរបរគុណនេយ្យ មានទីលំនៅភូមិ[redacted]។

**រឿងរ៉ាវហេតុមានដូចតទៅ**

តាមពាក្យបណ្តឹងចុះថ្ងៃទី ២២-៣-២០១១ របស់ឈ្មោះ [redacted] អិឈី បានបញ្ជាក់ថា កាលពីថ្ងៃទី ១៨-៣-២០១១ វេលាម៉ោង ២០.៣០នាទីយប់ មានសន្តិសុខ និងកម្មករមួយក្រុមមានគ្នាចំនួន ៦នាក់ មានឈ្មោះ [redacted] វាសនា,[redacted] ទុំ, [redacted] ថា , [redacted] បូរី ,[redacted] ហុង និងម្នាក់ទៀតមិនស្គាល់ឈ្មោះ បានឃុបឃិតគ្នាកាត់សោរពេងចក្រចូលយកខោអាវរោងចក្រអស់ចំនួន ១៦.៥កាតុង គឺស្មើនឹង៦៥៧អាវ។

-បានឃើញសាលក្រមព្រហ្មទណ្ឌលេខ ៨៣"ខ" ចុះថ្ងៃទី ២០-១០-២០១១ របស់សាលាដំបូងខេត្តតាកែវ ដែលមានខ្លឹមសារសម្រេចដូចខាងក្រោម៖

១-ផ្តន្ទាទោស

ក/-ឈ្មោះ [redacted] ថា ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ

ខ/-ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ

គ/-ឈ្មោះ [redacted] បូរី ភេទស្រី អាយុ៣១ឆ្នាំ ជាតិខ្មែរ

ដាក់ពន្ធនាគារក្នុងម្នាក់ៗ កំណត់រយៈពេល ០៤ឆ្នាំ(បួនឆ្នាំ) ពីបទ លួចដោយសាការប្រព្រឹត្តអំពើហិង្សា ប្រព្រឹត្តនៅភូមិឃ្លាំងសម្បត្តិ ឃុំពត់ស ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី ១៨-៣-១១ តាមមាត្រា ៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌ។

ឃ/-ឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ឆ្នាំ(បីឆ្នាំ) អនុវត្តក្នុងពន្ធនាគារ ០៣ខែ២៤ថ្ងៃ សល់ពីនេះព្យួរធម្មតា ពីបទ សមគំនិតក្នុងអំពើលួចដោយសារការប្រព្រឹត្តហិង្សា ប្រព្រឹត្តនៅភូមិឃ្លាំងសម្បត្តិ ឃុំពត់ស ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី ១៨-៣-២០១១ តាមមាត្រា ២៩,៣៥៣,៣៥៧, ១០៧ នៃក្រមព្រហ្មទណ្ឌ។

ង/-ឈ្មោះ [redacted] ទុំ ភេទប្រុស អាយុ១៨ឆ្នាំ ជាតិខ្មែរ ជាតិខ្មែរ ដាក់ពន្ធនាគារកំណត់រយៈពេល ០៣ឆ្នាំ(បីឆ្នាំ) តែទោសនេះអនុវត្តក្នុងពន្ធនាគារ ០៧ខែ (ប្រាំពីរខែ) ទោសសល់ពីនេះព្យួរធម្មតា។

ពីបទ: សមគំនិតក្នុងអំពើ លួចដោយសារការប្រព្រឹត្តហិង្សា ប្រព្រឹត្តនៅភូមិឃ្លាំងសម្បត្តិ

ឃុំពុតស ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី ១៨-៣-២០១១ តាមមាត្រា ២៩,៣៥៣,៣៥៧, ១០៧ នៃក្រមព្រហ្មទណ្ឌ។

២-បញ្ឈប់ការចាប់ខ្លួនលើឈ្មោះ [redacted] ថា ភេទប្រុស អាយុ២១ឆ្នាំ ជាតិខ្មែរ តាមដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៧៨ ចុះថ្ងៃទី ០៤-៥-២០១១ , ឈ្មោះ [redacted] ហុង ភេទប្រុស អាយុ២៥ឆ្នាំ ជាតិខ្មែរ តាមដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៧៧ ចុះថ្ងៃទី ០៤-៥-២០១១ , ឈ្មោះ [redacted] បូរី ភេទស្រី អាយុ៣១ ឆ្នាំ ជាតិខ្មែរ តាមដីកាបង្គាប់ឱ្យចាប់ខ្លួនលេខ ៧៩ ចុះថ្ងៃទី ០៤-៥-២០១១ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តតាកែវ តាមនីតិវិធី។

៣-សម្រេចចេញដីកាបង្គាប់ឱ្យចាប់ខ្លួន និងឃុំខ្លួនលើឈ្មោះ [redacted] ថា ,ឈ្មោះ [redacted] ហុង និងឈ្មោះ [redacted] បូរី តាមមាត្រា ៣៥៣ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

៤-វត្ថុតាងរូមមានដែកទីបជ្រុងប្រវែង ០២តឹក ទំហំ ២ គុណ ២ស.ម ចំនួន ០១ និងមេសោរពណ៌ខ្មៅខូចគុណភាពចំនួន០១ ដូចមានកំណត់ហេតុទទួលវត្ថុតាងរបស់តំណាងមហាអយ្យការអមសាលាដំបូងខេត្តតាកែវ ចុះថ្ងៃទី ២៣-៣-២០១១ ត្រូវរឹបអូស និងបំផ្លាញចោល។

៥-ទុកសិទ្ធិឱ្យដើមបណ្តឹងទាមទារសំណងជាក្រោយទៅតាមច្បាប់។

៦-បង្វិលសំណុំរឿងព្រហ្មទណ្ឌលេខ ៨២ ចុះថ្ងៃទី ២៣-៣-២០១១ ទៅអយ្យការអមសាលាដំបូងខេត្តតាកែវ ដើម្បីបើកការស៊ើបសួរលើកម្មករម្នាក់មិនស្គាល់ឈ្មោះភេទប្រុស ពីបទ អំពើលួចដោយសារការប្រព្រឹត្តអំពើហឹង្សា ប្រព្រឹត្តនៅក្នុងរោងចក្រប្លូសាមអេនធីរីខេមបូឌា ភូមិឃ្លាំងសម្បត្តិ ឃុំពុតស ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី ១៨-៣-២០១១ តាមមាត្រា ៣៥៣,៣៥៧ នៃក្រមព្រហ្មទណ្ឌតាមនីតិវិធី។

៧-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៥-១០-២០១១ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២០-១០-២០១១ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ទុំ ,មេធាវីការពារជនជាប់ចោទឈ្មោះ [redacted] កនតារា កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] ថា, ឈ្មោះ [redacted] ហុង ,ឈ្មោះ [redacted] បូរី ,ឈ្មោះ [redacted] វាសនា និងកំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] អិឈី បើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញសាលក្រមព្រហ្មទណ្ឌកំបាំងមុខលេខ ៣៩"ខ" ចុះថ្ងៃទី ២០-១១-២០១២ របស់សាលាដំបូងខេត្តតាកែវ ដែលមានខ្លឹមសារសម្រេចដូចខាងក្រោម៖

១-ទទួលពាក្យបណ្តឹងទាស់លេខ ៦៦ ចុះថ្ងៃទី ០១-១១-២០១២ របស់ឈ្មោះ [redacted] ហុង ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៨៣"ខ" ចុះថ្ងៃទី ២០-១០-២០១១ របស់សាលាដំបូងខេត្តតាកែវ ទុកជាបានការ។

៣-សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី ០៧-១១-២០១២ និងប្រកាសជាសាធារណៈនៅថ្ងៃទី ២០-១១-២០១២ ចំពោះមុខជនជាប់ចោទឈ្មោះ [redacted] ហុង ,មេធាវីការពារជនជាប់

ចោទ បើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

-បានឃើញបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៦-១២-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] **ហុង** សុំប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៩"ខ" ចុះថ្ងៃទី ២០-១១-២០១២ របស់សាលាដំបូងខេត្តតាកែវ លើចំណុចនៃសេចក្តីសម្រេចទាំងមូល។

-បានឃើញរបាយការណ៍របស់ចៅក្រមសាលាឧទ្ធរណ៍ចុះថ្ងៃទី ២៣-៤-២០១៣។

-បានឃើញសេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការចុះថ្ងៃទី ១៤-៨-២០១៣។

## នាពេលសវនាការសាលាឧទ្ធរណ៍

ចៅក្រមអានរបាយការណ៍រឿង

-ក្រឡាបញ្ជីអានចម្លើយឈ្មោះ [redacted]

-ឈ្មោះ [redacted] ហុង បាឆ្លើយថា ខ្លួនប្តឹងឧទ្ធរណ៍ដោយសារចោទប្រកាន់ពីបទលួចហឹង្សាដោយខ្លួនគ្រាន់ទៅតាមការបបួលរបស់ឈ្មោះ [redacted] ថា ពុំបានប្រើហឹង្សាផង។ ក្នុងអង្គហេតុនេះ ឈ្មោះ [redacted] ថា បានបបួលខ្លួនទៅជាមួយគេ តែខ្លួនមិនព្រមទៅ ក្រោយពីបានផឹកស្រាមួយកែវមកខ្លួនព្រមទៅ ដោយមិនបានប្រព្រឹត្តអ្វីទេ គ្រាន់តែបានរួមដំណើរជាមួយគេ និងបានយកខោអាវមួយស្បោងតូច ក្រៅពីនេះខ្លួនមិនបានដឹងទេ ក្រោយមកគេយកទៅលក់បានប្រាក់ ២៥ម៉ឺនរៀលចែកគ្នា៥នាក់ ខ្លួនទទួលបាន៥ម៉ឺនរៀលដែរ រីឯអ្នកកាត់សោរ គឺឈ្មោះ [redacted] ថា ពេលខ្លួនទៅដល់គេគាស់ទ្វាររួចហើយ ។ ខ្លួនទើបប្រព្រឹត្តបទល្មើសតែម្តងនេះទេ និងសំណូមពរចុងក្រោយសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាជួយបន្ធូបន្ថយទោសដល់ខ្លួន។

## តំណាងមហាអយ្យការធ្វើសេចក្តីសន្និដ្ឋានថា

១-ជនជាប់ចោទបានឆ្លើយសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួនហើយ ដូច្នេះមានភស្តុតាងគ្រប់គ្រាន់ដូចសេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការថ្នាក់ក្រោមហើយ។

២-សំអាងហេតុ និងសេចក្តីសម្រេចរបស់តុលាការថ្នាក់ក្រោមមានលក្ខណៈច្បាស់លាស់សុំតម្កល់សាលក្រមទុកជាបានការ។

-មេធាវី [redacted] សារី ការពារសិទ្ធិឱ្យឈ្មោះ [redacted] ហុង បានធ្វើសេចក្តីសន្និដ្ឋានថា កូនក្តីខ្លួនបានទទួលស្គាល់កំហុសរបស់ខ្លួន ហើយការចូលរួមប្រព្រឹត្តនេះទៀតសោតដោយមានការបបួលជាច្រើនលើកពីឈ្មោះ [redacted] ថា ព្រមទាំងខ្លួនមានភាពស្រវឹងក៏បានទៅជាមួយគេ ម៉្យាងទៀតកូនក្តីខ្លួនពុំមានឆន្ទៈ និងផ្តើមគំនិតទេ ឬ កាត់សោរទំលុះទំលាយឡើយ។ នៅពេលនេះគាត់សារភាពទទួលកំហុស និងសុំឱ្យតុលាការជួយផ្តល់ស្ថានសំរាលដល់គាត់ បើយោងតាមមាត្រា ៩៣ ,៩៤ ដើម្បីឱ្យគាត់បានកសាងខ្លួនរស់នៅក្នុងសង្គមវិញ ហើយការផ្តន្ទាទោសគាត់ស្មើនឹងអ្នកផ្តើមគំនិត និងគាស់ទំលុះទំលាយរហូតដល់ ០៤ឆ្នាំ មានលក្ខណៈធ្ងន់ធ្ងរពេក។ ក្នុងនាមខ្លួនជាមេធាវីក៏សំណូមពរសុំឱ្យក្រុមប្រឹក្សាជំនុំជម្រះមេត្តាផ្តល់ស្ថានសំរាលនៅកំរិតក្រោមអប្បរមានៃទោស ហើយទោស

ដែលនៅសល់សុំល្បរ។

## សភាព្រហ្មទណ្ឌយល់ឃើញថា

១-បណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៦-១២-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ហុង ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ៣៩"ខ" ចុះថ្ងៃទី ២០-១១-២០១២ របស់សាលាដំបូងខេត្តតាកែវ ធ្វើឡើងក្នុងកំណត់ច្បាប់ តាមមាត្រា ៣៨២ នៃក្រមនីតិវិធីព្រហ្មទណ្ឌ សភាព្រហ្មទណ្ឌអាចទទួលជំនុំជម្រះបាន។

២-ជនជាប់ចោទឈ្មោះ [redacted] ហុង បានទទួលស្គាល់នូវអំពើប្រព្រឹត្តរបស់ខ្លួនដូចការចោទប្រកាន់ ប៉ុន្តែជនជាប់ចោទរូបនេះបានសុំឱ្យសភាព្រហ្មទណ្ឌបន្ធូបន្ថយទោសដល់ខ្លួន ដើម្បីខ្លួនបានទៅប្រកបមុខរបរចិញ្ចឹមឪពុកម្តាយចាស់ វិញ។

៣-រឿងក្តីនេះសាលាដំបូងបានធ្វើការស៊ើបសួរ និងលើកយកសំអាងហេតុមកបញ្ជាក់មានលក្ខណៈត្រឹមត្រូវហើយ ហេតុដូច្នេះសភាព្រហ្មទណ្ឌឯកភាពតាមសំអាងហេតុនេះ ពុំចាំបាច់លើកយកសំអាងហេតុដដែលនេះមកបញ្ជាក់ជាថ្មីទៀតឡើយ។

៤-មានពិរុទ្ធភាពគ្រប់គ្រាន់លើឈ្មោះ [redacted] ហុង ពីបទៈ លួចដោយសារការប្រព្រឹត្តអំពើហឹង្សា ប្រព្រឹត្តនៅភូមិឃ្លាំងសម្បត្តិ ឃុំពត់ស ស្រុកបាទី ខេត្តតាកែវ កាលពីថ្ងៃទី ១៨-៣-២០១១ តាមមាត្រា ៣៥៧ នៃក្រមព្រហ្មទណ្ឌ។

៤-ជនជាប់ចោទបានសារភាពនូវអំពើប្រព្រឹត្តរបស់ខ្លួន, ជនជាប់ចោទរូបនេះទើប្រព្រឹត្តបទល្មើសជាលើកដំបូង ,ដោយសារគំរិតវប្បធម៌ទាប ខ្វះការយល់ដឹង, ហើយជនជាប់ចោទរូបនេះពេលទទួលទោសកន្លងមកមានការកែប្រែច្រើន ដូច្នេះគប្បីក្រុមប្រឹក្សាពិចារណាអំពីកំរិតទណ្ឌកម្មឱ្យបានធូនល្មមតាមច្បាប់។

៥-សាលក្រមព្រហ្មទណ្ឌលេខ ៣៩"ខ" ចុះថ្ងៃទី ២០-១១-២០១២ របស់សាលាដំបូងខេត្តតាកែវ សម្រេចសេចក្តីមានលក្ខណៈត្រឹមត្រូវហើយ លើកលែងតែចំណុចស្តីពីទណ្ឌកម្មលើឈ្មោះ [redacted] ហុង គួរបន្ធូបន្ថយមកត្រឹមចំនួន ០៣ឆ្នាំ (បីឆ្នាំ) វិញ ចំណុចផ្សេងពីនេះរក្សាទុកជាបានការដដែល។

**ហេតុដូច្នេះ**

## ទនិច្ឆ័យសេចក្តី

១-ទទួលបណ្តឹងឧទ្ធរណ៍ចុះថ្ងៃទី ០៦-១២-២០១២ របស់ជនជាប់ចោទឈ្មោះ [redacted] ហុង ទុក ជាត្រឹមត្រូវតាមច្បាប់។

២-តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ៣៩"ខ" ចុះថ្ងៃទី ២០-១១-២០១២ របស់សាលាដំបូងខេត្តតាកែវ ទុកជាបានការ លើកលែងតែចំណុចទី១ "ខ" ស្តីពីទណ្ឌកម្មលើឈ្មោះ [redacted] ហុង ចំនួន ០៤ឆ្នាំ ត្រូវបន្ថយមកនៅត្រឹមចំនួន ០៣ឆ្នាំ (បីឆ្នាំ) វិញ។ ចំណុចផ្សេងពីនេះរក្សាទុកជាបានការដដែល។

៣-បន្តការឃុំខ្លួនជនជាប់ចោទតាមច្បាប់។

៤-សាលដីកានេះប្រកាសជាសាធារណៈនៅថ្ងៃទី ០៩-១០-២០១៤ ចំពោះមុខមេធាវីការពារសិទ្ធិជនជាប់ចោទ និងជនជាប់ចោទ, កំបាំងមុខដើមបណ្តឹងរដ្ឋប្បវេណី។

-បើកផ្លូវប្តឹងតវ៉ាតាមកំណត់ច្បាប់។

**សេចក្តីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកំលាំងប្រដាប់អាវុធគ្រប់ថ្នាក់ គ្រប់កំណែង ជួយសហការអនុវត្តសាលដីកានេះឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា | ហត្ថលេខា | ហត្ថលេខា |
| [redacted] | [redacted] . [redacted] | [redacted] |

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម។

បានឃើញ

សាលាឧទ្ធរណ៍ថ្ងៃទី 31 ខែ 12 ឆ្នាំ ២០១៤

**ប្រធានសាលាឧទ្ធរណ៍**

[redacted]

**ក្រឡាបញ្ជី**

[redacted]